01704263

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

F71/1/1/6

# អនុស្សរណៈអន្តរការិយាល័យ

**ជូនចំពោះ** ៖ ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល

**ពី** ៖ អង្គភាពគាំពារការពារក្តី

**កាលបរិច្ឆេទ** ៖ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២

**កម្មវត្ថុ** ៖ ចម្លើយតបទៅនឹង "ការពិនិត្យឡើងវិញលើឯកសារសម្ងាត់ និងសម្ងាត់បំផុតក្នុងសំណុំរឿង០០២" របស់អង្គជំនុំជម្រះតុលាការកំពូល

---

1. អង្គជំនុំជម្រះតុលាការកំពូលបានចេញ "ការពិនិត្យឡើងវិញលើកឯកសារសម្ងាត់ និងសម្ងាត់បំផុតក្នុងសំណុំរឿង០០២"[1] ដោយអញ្ជើញអង្គជំនុំជម្រះនានាក្នុងតុលាការនេះ ការិយាល័យសហចៅក្រមស៊ើបអង្កេត និងភាគីនានា ព្រមទាំងអង្គភាពគាំពារការពារក្តី អង្គភាពគាំពារជនរងគ្រោះ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ផ្នែកគ្រប់គ្រងតុលាការ និងការិយាល័យរដ្ឋបាល ឱដាក់សេចក្តីអង្កេតរបស់ខ្លួនលើ (i) គោលការណ៍ណែនាំដែលស្នើឡើងសម្រាប់ធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ និង (ii) អត្ថិភាពនៃការសម្ងាត់នៃកិច្ចស៊ើបសួរតាមផ្លូវតុលាការក្នុងសំណុំរឿង០០២[2] ហើយអង្គជំនុំជម្រះតុលាការកំពូលបានស្នើឱអង្គភាពគាំពារការពារក្តីប្រាកដថាមានការពិគ្រោះយោបល់ជាមួយមេធាវីការពារក្តីមុនដាក់សេចក្តីអង្កេតរបស់ខ្លួន។

2. អង្គភាពគាំពារការពារក្តី គាំទ្រចំពោះគោលការណ៍ណែនាំដែលស្នើឡើងដោយអង្គជំនុំជម្រះតុលាការកំពូលសម្រាប់ធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ។ អង្គភាពគាំពារការពារក្តីយល់ឃើញថាព័ត៌មាន

---

[1] អនុស្សរណៈអន្តរការិយាល័យរបស់អង្គជំនុំជម្រះតុលាការកំពូល ការពិនិត្យឡើងវិញលើឯកសារសម្ងាត់ និងសម្ងាត់បំផុតក្នុងសំណុំរឿង០០២ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២ ឯកសារF71/1/1 ("ការអញ្ជើញរបស់អង្គជំនុំជម្រះតុលាការកំពូល (F71/1/1) ")។

[2] ("ការអញ្ជើញរបស់អង្គជំនុំជម្រះតុលាការកំពូល (F71/1/1)") កថាខណ្ឌទី៥។

ទាំងឡាយណាដែលពាក់ព័ន្ធនឹងសុខភាពរបស់ជនជាប់ ចោទ ខៀវ សំផន ត្រូវតែរក្សាជាការសម្ងាត់បំផុតបន្តទៀត។

3. ការឆ្លើយតបនេះធ្វើឡើងបន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយមេធាវីការពារក្តី។

ដោយក្តីគោរព

គង់ សុគន្ធ

មន្ត្រីទទួលបន្ទុក នៃអង្គភាពគាំពារការពារក្តី

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ០២៣-២១៩-៨១៤ ទូរសារ (៨៥៥) ០២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh